**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

លេខ: ៤១៥៤ សក

## បទបញ្ជាផ្ទៃក្នុងស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
## ក្រសួងសាធារណការនិងដឹកជញ្ជូន

ដើម្បីចូលរួមគោរពច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកឲ្យមានប្រសិទ្ធភាព និងផ្ដល់ភាពជាគំរូដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកប្រើប្រាស់ផ្លូវនូវឥរិយាបថប្រកបដោយសុវត្ថិភាព មន្ត្រីរាជការ និយោជិតទាំងអស់ក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តបទបញ្ជាដូចខាងក្រោម៖

១. ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវទាំងអ្នកបើកបរ និងអ្នករួមដំណើរ រាល់ពេលធ្វើដំណើរតាមទោចក្រយានយន្ត និងត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពទាំងអ្នកបើកបរ និងអ្នករួមដំណើរនៅពេលធ្វើដំណើរតាមរថយន្ត គ្រប់ពេលវេលា ទោះទៅទីជិត ឬទីឆ្ងាយ។

២. មិនត្រូវបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន និងកុំបើកបរក្នុងស្ថានភាពងងុយដេក។ មិនត្រូវប្រើប្រាស់ទូរស័ព្ទ ដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនងក្នុងពេលបើកបរ។

៣. ត្រូវបើកបរគោរពតាមល្បឿនដែលបានកំណត់ទៅតាមប្រភេទយានយន្តរបស់ខ្លួន គឺ ៣០គីឡូម៉ែត្រក្នុងមួយម៉ោងសម្រាប់ម៉ូតូ និង៤០គីឡូម៉ែត្រក្នុងមួយម៉ោង សម្រាប់រថយន្តនៅក្នុងទីប្រជុំជន និង៨០គីឡូម៉ែត្រក្នុងមួយម៉ោង សម្រាប់រថយន្តធុនស្រាលនៅក្រៅទីប្រជុំជន។ ត្រូវបន្ថយល្បឿននៅកន្លែងផ្លូវប្រសព្វ ផ្លូវកោង ផ្លូវតូចចង្អៀត ផ្លូវគ្រលុក និងទៅតាមតំបន់ដូចជា សាលារៀន ផ្សារ រោងចក្រនៅជាប់តាមដងផ្លូវ។

៤. ត្រូវបើកបរដោយគោរពសិទ្ធិអាទិភាពនៅកន្លែងផ្លូវប្រសព្វ និងមិនត្រូវបើកបរជែងក្នុងស្ថានភាពគ្រោះថ្នាក់ ព្រមទាំងមិនត្រូវផ្ទុកមនុស្សលើសចំណុះកំណត់។

៥. ត្រូវត្រួតពិនិត្យសុវត្ថិភាពយានយន្តមុននឹងបើកបរ ជាពិសេស ហ្វ្រាំង ចង្កូត កង់ និងភ្លើង។ ត្រូវមានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត បណ្ណសម្គាល់យានយន្ត និងបណ្ណបើកបរតាមប្រភេទយាន។

៦. ត្រូវពាក់អាវពណ៌ដែលមានពន្លឺអាចឲ្យគេមើលឃើញ សម្រាប់អ្នកជិះកង់ និងថ្មើរជើង ដែលធ្វើដំណើរតាមដងផ្លូវ ឬឆ្លងកាត់ផ្លូវនៅពេលយប់។

៧. ការបំពាន ឬប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង មន្ត្រីរាជការ និយោជិត នឹងត្រូវបានជូនដំណឹងជាបន្ទាន់ទៅអង្គភាពសាមីធ្វើការណែនាំ ហើយកត់ត្រាទុកនូវកំហុស ដើម្បីដាក់បញ្ចូលក្នុងការវាយតម្លៃនៅពេលដំឡើងឋានៈ តួនាទី ឬការផ្ដល់រង្វាន់លើកទឹកចិត្តនានា។

៨. មន្ត្រីរាជការ និយោជិតទាំងអស់ក្រោមឱវាទក្រសួង ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងនេះ និងជួយអប់រំណែនាំ ផ្សព្វផ្សាយបន្តដល់សមាជិកគ្រួសារ និងមិត្តភក្តិ ដើម្បីជួយជំរុញឲ្យមានការចូលរួមទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលបង្កឲ្យមានអ្នករងគ្រោះដល់បាត់បង់ជីវិត ឬរបួស ពិការ និងខូចខាតទ្រព្យសម្បត្តិឯកជន និងសាធារណៈ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

មហាវិថីព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៨៨ ៣៨ ៧៤, (៨៥៥) ២៣ ៨៨ ២៩ ៦៥